# សម្ភាសន៍ជាមួយឈ្មោះ ធិប អឿន ភេទប្រុស អាយុ៥១ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ កងចល័ត

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិអន្គ ឃុំតាមើល ស្រុកថ្មគោល ខេត្តបាត់ដំបង

សព្វថ្ងៃរស់នៅភូមិអូរកណ្ដាល ឃុំអូររំដួល ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១:១១:៥៧

៣៣ទំព័រ

ដានី : ចឹងជំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ឈ្មោះពេញឈ្មោះអីដែរ?

អឿន : ធិប អឿន ។

ដានី : សព្វថ្ងៃអាយុប៉ុន្មានហើយ?

អឿន : ៥១ ។

ដានី : ស្រុកកំណើតកើតជាពូនៅភូមិឃុំស្រុកអីដែរ?

អឿន : នៅថ្មគោល ឃុំតាមើង ។

ដានី : កំណើតភូមិថ្មគោល?

អឿន : អត់ទេ ភូមិអន្គ ឃុំតាមើង តែពីដើមគេដាក់ស្រុកបាត់ដំបង តែឥឡូវជាស្រុកថ្មគោលហើយ ។

ដានី : សព្វថ្ងៃពូរស់នៅភូមិឃុំស្រុកអី?

អឿន : ភូមិអូរកណ្ដាល ឃុំអូររំដួល ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបងដែរ ។

ដានី : មីងប្រពន្ធពូ គាត់ឈ្មោះអីដែរ?

អឿន : សៅ សារ៉ន ។

ដានី : សៅ សារ៉ន?

អឿន : បាទ!

ដានី : គាត់អាយុប៉ុន្មានហើយ?

អឿន ៖ អាយុ៥០ ។

ដានី ៖ អាយុ៥០?

អឿន ៖ បាទ!

ដានី ៖ មីងគាត់អ្នកស្រុកកំណើតគាត់នៅណាដែរ?

អឿន ៖ នៅកំពត ។

ដានី ៖ កំពត នៅភូមិឃុំអីដែរ?

អឿន ៖ មិនដឹងស្អី ។

ដានី ៖ អត់ចាំ?

អឿន ៖ ចាំតើ ។

ប្រពន្ធ ៖ ចាំតែភូមិព្រៃជុំ ។

ដានី ៖ ឃុំ?

ប្រពន្ធ ៖ អត់ដឹង ។

អឿន ៖ អត់ដឹង ។ ភូមិដឹង ។

ប្រពន្ធ ៖ ភ្លេចអស់ហើយ ។

ដានី ៖ ភូមិព្រៃជុំ អត់ដឹងស្រុកអីទេ?

ប្រពន្ធ ៖ ស្រុក អឺ! ស្រុកឈូកខេត្តកំពតនឹង ស្រុកឈូក ខេត្តកំពត ដឹងឃុំអីទេ ភ្លេចបាត់ហើយ មិនបានទៅក៏មិនដែលបានចាំភ្លេច ។

ដានី ៖ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់?

អឿន ៖ ៤ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

អឿន ៖ ប្រុស២ ស្រី២ ។

ដានី ៖ សព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

អឿន ៖ អឺ! និយាយពីប្រកបមុខរបរ គឺធ្វើខ្ញុំគេនឹងហើយ អត់មានបានធ្វើអីទេ ព្រោះវាអស់ដី អស់ធ្លី ហើយម្យ៉ាងខ្ញុំកាលពីគេក្តាប់រំសាយកងទ័ពនោះ ខ្ញុំអត់ដែលបានទៅកាត់រំសាយនឹងគេ ។ គេផ្តាច់ កាត់ឈ្មោះយកអស់ហើយ ។

ដានី ៖ រាល់ថ្ងៃយើងស៊ីឈ្នួលគេទៅ?

អឿន ៖ បាទ!

ដានី ៖ អត់មានដីធ្លីធ្វើចំការ?

អឿន ៖ វាមានៗតិចតួចដែរ វាមិនមែនអត់សោះទេ មានដីក្រោយផ្ទះម៉ាឡូត៍នឹងឯង។

ដានី ៖ ចុះពូ ឪពុកពូគាត់ឈ្មោះអីដែរ?

អឿន ៖ ដុក ។

ដានី ៖ អីដុក?

អឿន ៖ អឺ! ឆិប ដុបនឹងហើយ ឪគាត់។

ដានី ៖ ដុប សព្វថ្ងៃគាត់នៅរស់ ឬក៏ស្លាប់?

អឿន ៖ បាទ! នៅរស់។

ដានី ៖ គាត់នៅរស់។ រស់នៅភូមិណាដែរ?

អឿន ៖ នៅអន្លក់នឹង។

ដានី ៖ នៅស្រុកកំណើត?

អឿន ៖ បាទ!

ដានី ៖ ម្ដាយ?

អឿន ៖ ម្ដាយ ប្រឹង លឹម ។

ដានី ៖ ប្រឹង លឹម គាត់នៅរស់ដែរ?

អឿន ៖ បាទ!

ដានី ៖ នៅភូមិណាដែរ?

អឿន ៖ នៅជាមួយគ្នានឹង អន្លក់ដែរ ។

ដានី ៖ ចុះពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

អឿន ៖ បងប្អូនបង្កើតខ្ញុំ៧នាក់។

ដានី ៖ ៧នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អឿន ៖ ប្រុស៥ ស្រី២ ។

ដានី ៖ ស្រី២?

អឿន ៖ បាទ!

ដានី ៖ ពូកូនទីប៉ុន្មាន?

អឿន ៖ ខ្ញុំកូនទី៣ ។

ដានី ៖ កូនទី៣ កាលពីក្មេងៗពូបានរៀនសូត្រអីដែរ?

អឿន ៖ អត់ ។

ដានី ៖ អត់បានរៀនសូត្រ អត់បានទៅសាលារៀន?

អឿន ៖ បាទៗ ។

ដានី ៖ ពូចេះអានចេះសរសេរដែរអត់?

អឿន ៖ ចេះ ។

ដានី ៖ ចេះមើលដាច់?

អឿន ៖ បាទ! ដាច់ទាំងអស់ ។

ដានី ៖ អត់បានទៅរៀន ប៉ុន្តែមើលដាច់?

អឿន ៖ ខ្ញុំរៀនកាលសម័យយើងតស៊ូនឹង ។

ដានី ៖ រៀនតាំងពីសម័យតស៊ូ?

អឿន ៖ បាទ!

ប្រពន្ធ ៖ រៀនក្នុងព្រៃខ្លួនឯង គ្មានអ្នកណាគេបង្រៀន ។

ដានី ៖ ចឹងកាលពីក្មេងៗពូនៅជាមួយក្រុមគ្រួសារ ឬក៏យ៉ាងម៉េច?

អឿន ៖ បាទ! ខ្ញុំនៅជាមួយឪពុកមាខ្ញុំ ។

ដានី ៖ នៅជាមួយឪពុកមានៅណាទៅ?

អឿន ៖ ឪពុកមាខ្ញុំនៅភូមិតាពូង ។

ដានី ៖ នៅតាពូងៗនៅណាទៅ?

អឿន ៖ នៅម្តុំថ្មគោលនឹងដែរ ចូលខាងក្រោមថ្មគោល ក្រោមផ្ទះខ្ញុំ ទៅជាប់មាត់រនាមនឹង ព្រៃទន្លេសាប ។

ដានី ៖ គាត់ធ្វើអីទៅ?

អឿន ៖ គាត់ធ្វើស្រែ ។

ដានី ៖ នៅជាមួយគាត់បានប៉ុន្មានដែរ?

អឿន ៖ ខ្ញុំនៅជាមួយគាត់បាន៣-៤ឆ្នាំដែរ ។

ដានី ៖ នៅជាមួយគាត់ធ្វើអីទៅ?

អឿន ៖ ធ្វើស្រែ មើលគោមើលអី ។

ដានី ៖ បន្ទាប់ពីនៅជាមួយគាត់នឹងនៅជាមួយអ្នកណាទៀត?

អឿន ៖ បន្ទាប់ពីនឹងមកយើងកាលពីយើង៧៥ ។

ដានី ៖ ចឹងមើលគោរហូតដល់៧៥?

អឿន ៖ បាទ! អត់ទេ ឪពុកមាខ្ញុំគាត់ទៅធ្វើខ្មែរក្រហមបានម៉ាឆ្នាំ កាលនឹងខ្ញុំមកនៅផ្ទះវិញមក ។

ដានី ៖ ឪពុកមាគាត់អត់ទាន់មានប្រពន្ធមានកូន?

អឿន ៖ មាន ។

ដានី ៖ គាត់ចូលជាមួយខ្មែរក្រហមនឹង?

អឿន ៖ បាទ!

ដានី ៖ ពូក៏ត្រឡប់មកផ្ទះវិញ?

អឿន ៖ បាទ!

ដានី ៖ ត្រឡប់មកផ្ទះវិញធ្វើអីទៅ?

អឿន ៖ អត់មានបានធ្វើអី ជួយរកត្រីរកអីឪពុកម្ដាយ ។

ដានី ៖ ជួយរញត្រី?

អឿន ៖ បាទ!

ដានី ៖ រហូតដល់ណា?

អឿន ៖ រហូតដល់រំដោះ៧៥ ។

ដានី ៖ ដល់ពេលរំដោះឆ្នាំ៧៥ យ៉ាងម៉េចទៅ?

អឿន ៖ រំដោះឆ្នាំ៧៥ ខ្ញុំទទួលបែកពីឪពុកម្ដាយខ្ញុំ នៅកុមារ ។

ដានី ៖ នៅកន្លែងកុមារ?

អឿន ៖ បាទ!

ដានី ៖ កាលនោះពូនៅក្មេងនៅឡើយ?

អឿន ៖ បាទៗ ក្មេង ។

ដានី ៖ អាយុប៉ុន្មានកាលនោះ?

អឿន ៖ នឹងខ្ញុំអាយុ១៥ឆ្នាំ ។

ដានី ៖ គេឲ្យធ្វើអីខ្លះទៅ កាលនៅកុមារ?

អឿន ៖ កាលនឹងគេឲ្យធ្វើ មានអីជីកតែប្រឡាយ ធ្វើស្រែដូចយើងនៅដើមនេះ ។

ដានី ៖ ជីកប្រឡាយធ្វើស្រែរហូតដល់ពេលណាទៅ?

អឿន ៖ រហូតដល់ឆ្នាំ៧៦ ខ្ញុំទៅនៅជាមួយឪពុកមាខ្ញុំ ។

ដានី ៖ ឆ្នាំ៧៦ ពូទៅនៅជាមួយឪពុកមាវិញ?

អឿន ៖ បាទ!

ដានី ៖ ឪពុកមាដែលពូធ្លាប់ទៅនៅជាមួយមុន?

អឿន ៖ អត់ទេ នេះឪពុកមាមួយទៀត កូនពៅជីតាខ្ញុំ ។

ដានី ៖ គាត់ធ្វើអីឪពុកមាពូ?

អឿន ៖ កាលនឹងគាត់នៅក្ដាប់ចល័ត គាត់នៅធ្វើប្រធានចល័តនៅវាលទ្រា ។

ដានី ៖ ចឹងចល័តនៅ?

អឿន ៖ វាលទ្រា ។

ដានី ៖ វាលទ្រានៅណាទៅ?

អឿន ៖ វាលទ្រាអូរសង្កែ ផ្លូវទៅបាត់ដំបងនឹង អូរសង្កែ អូរតាគី ។

ដានី ៖ គាត់ធ្វើប្រធានចល័តនឹង ចល័តរបស់អីគេ របស់ស្រុក ឬរបស់អីគេ?

អឿន ៖ អឺ! បើនិយាយទៅ ប្រហែលជាកាលនឹងមិនមែនស្រុក អាចភាគ ។

ដានី ៖ អាចភាគ?

អឿន ៖ បាទ!

ដានី ៖ ចល័តភូមិភាគ?

អឿន ៖ បាទ!

ដានី ៖ គាត់ក្ដាប់គ្នាច្រើន ចល័តរបស់គាត់?

អឿន ៖ បាទ?

ដានី ៖ ចល័តឪពុកមាររបស់ពូក្ដាប់នឹង ក្ដាប់គ្នាច្រើន ក៏នៅ?

អឿន ៖ ច្រើន ។

ដានី ៖ ប្រហែលប៉ុន្មានទៅ?

អឿន ៖ យ៉េ! បើតាមគិតប្រហែលជា១០០០នាក់ដែរនឹង ។

ដានី ៖ ពូធ្វើអីទៅកាលនៅជាមួយគាត់?

អឿន ៖ ខ្ញុំអត់មានធ្វើអីផង ខ្ញុំនៅជាមួយគាត់ ។

ដានី ៖ ឪពុកមាពូគាត់ឈ្មោះអី?

អឿន ៖ ជួន ។

ដានី ៖ ឈ្មោះអីជួន?

អឿន ៖ ប្រឹង ជួន ។

ដានី : ចឹងកាលនឹងដល់ឆ្នាំ៧៦ ពេលដែលពូទៅនៅជាមួយគាត់ទៅ ពូអត់ធ្វើអីទេ អត់ធ្វើការងារជាមួយកងចល័តទេ?

អឿន : បាទ! អត់ទេ ។

ដានី : យើងនៅយើងធ្វើអីខ្លះ ដូចថា?

អឿន : ខ្ញុំនៅ គាត់ឲ្យនៅតែផ្ទះម៉ង ។

ដានី : គាត់ឲ្យនៅផ្ទះ?

អឿន : បាទ! នៅតែផ្ទះគាត់នឹង ។

ដានី : ចុះឪពុកមាពូ គាត់ធ្វើអីទៅ គាត់ដូចថាកងចលត័ គាត់ធ្វើ?

អឿន : គាត់ទៅជីកនាំកម្លាំងធ្វើ ជីកប្រឡាយ ជីកអីចឹងទៅ ធ្វើស្រែ ធ្វើអីចឹង ។

ដានី : ធ្វើស្រែ?

អឿន : បាទ!

ដានី : ពូនៅផ្ទះជាមួយគាត់គ្នាច្រើនដែរ?

អឿន : អត់ទេ តែ២នាក់គាត់ ។

ដានី : ២នាក់គាត់ៗអត់ទាន់មានប្រពន្ធទេ?

អឿន : បាទ! មានដែរ កាលនឹងប្រពន្ធនៅផ្សេង ប្ដីនៅផ្សេង ។

ដានី : អូ! ប្រពន្ធនៅផ្សេង ប្ដីនៅផ្សេង?

អឿន : បាទ!

ដានី : ចឹងគាត់ទៅធ្វើការអី ពូអត់ជូនគាត់ទៅទេ?

អឿន : អត់ទេ ។

ដានី : គាត់ឲ្យនៅផ្ទះ?

អឿន : បាទ!

ដានី : ចុះពូកាលនឹង បានហូបចុកអីគ្រប់គ្រាន់ដែរ?

អឿន : បាទ! ខ្ញុំអត់អី ខ្ញុំនៅនឹងហូបឆ្អែតៗ ។

ដានី : ហូបឆ្អែត?

អឿន : បាទ!

ដានី : អត់ពិបាកដូចអឺ?

អឿន : បាទ! អត់ទេ ។

ដានី ៖ ពូនៅជាមួយគាត់រហូត ។

អឿន ៖ បាទ! ខ្ញុំនៅមកដល់ឆ្នាំ៧៨ បានខ្ញុំបែកពីគាត់ ដល់បែកពីគាត់ៗត្រូវយកខ្ញុំមកដាក់កន្លែងកងចល័តចឹង រំលងប្រហែលជាកន្លះឆ្នាំ ខ្ញុំក៏មករកឪពុកម្ដាយខ្ញុំៗគាត់នៅអូរសង្កែ ។ ដល់ខ្ញុំមកនៅជាមួយឪពុកម្ដាខ្ញុំបានប៉ុន្មានខែ គេយកទៅដាក់កន្លែងចល័តនឹងដដែល រយៈប្រហែលជាកន្លះឆ្នាំ យួនចូលមកនឹង ខ្ញុំក៏រត់បែកពីឪពុកម្ដាយខ្ញុំមកនេះមក ។

ដានី ៖ ចឹងកាលចន្លោះពី៧៦ មកដល់៧៨នឹងពូនៅជាមួយឪពុកមានឹង ចឹងអត់ធ្វើអីទេ នៅតែផ្ទះជាមួយគាត់?

អឿន ៖ បាទៗ ។

ដានី ៖ ក៏ឪពុកមារបស់ពូគាត់ទៅធ្វើការហើយ ល្ងាចៗគាត់មកផ្ទះវិញ?

អឿន ៖ បាទ!

ដានី ៖ គាត់អត់ដែលទៅធ្វើការណាឆ្ងាយអី?

អឿន ៖ អត់ទេ ខ្ញុំធ្វើតែជិតៗនឹង ។

ដានី ៖ ពូក៏អត់មានចេញទៅធ្វើការដែរ នៅតែផ្ទះ?

អឿន ៖ បាទ!

ដានី ៖ នៅផ្ទះធ្វើអី អត់មាន មានគេដាំបាយឲ្យពូ ឬក៏ពូ?

អឿន ៖ អត់ទេ បាយកាលនឹងបាយរួមគេ ។

ដានី ៖ បាយរួម?

អឿន ៖ បាទ!

ដានី ៖ យើងទៅហូបបាយរួម?

អឿន ៖ អត់ទេ ពេលដែលគេដាំឆ្អិនអីឆ្អិន គេលើកយកមកឲ្យឪពុកមាចឹងមក ម៉ាឆ្នាំងចឹងមក ។

ដានី ៖ ហូបទាំងអស់គ្នាទៅ?

អឿន ៖ បាទ! ខ្ញុំហូបជាមួយគាត់ ។

ដានី ៖ ពូនៅកន្លែងណា នៅផ្ទះអីគេយ៉ាងម៉េច?

អឿន ៖ នៅមុំវាលទ្រានឹង មិនដឹងយ៉ាងម៉េច អានឹងពិបាកប្រាប់ណាស់ បើជិតស្ពានប្រស់ ។

ដានី ៖ កាលនឹងពូអត់មានកាំភ្លើងមានអី?

អឿន ៖ អត់ទេ កាលនឹងគេអត់ឲ្យប្រើកាំភ្លើង ។

ដានី ៖ អត់ឲ្យ?

អឿន ៖ បាទ!

ដានី ៖ ដូចថាឪពុកមាពូធ្វើធំអីចឹង គាត់មានកាំភ្លើងមានអី?

អឿន ៖ អត់ទេ ។ កាំភ្លើងកាលនឹងប្រើបានសម្រាប់កងទ័ព ។

ដានី ៖ ចុះម៉េចបានឆ្នាំ៧៨ បានឪពុកមាពូ យកពូមកដាក់កន្លែងកងចល័ត?

អឿន ៖ កាលនឹងគាត់ទៅក្តាប់កន្លែងឃុំវិញ អាគាត់ទៅនៅឃុំ ។

ដានី ៖ គាត់ទៅនៅឃុំ?

អឿន ៖ បាទ!

ដានី ៖ គាត់ទៅនៅឃុំណាវិញ?

អឿន ៖ គាត់ទៅនៅឃុំព្រៃស្តោ ។

ដានី ៖ នៅណាទៅព្រៃស្តោ?

អឿន ៖ ព្រៃស្តោក្រោមដូនទាវ ។

ដានី ៖ ដូនទាវ?

អឿន ៖ ចុះមកក្រោមដូនទាវមក ម្តុំពាមឯក ។ ស្គាល់ពាមឯក?

ដានី ៖ ស្គាល់ៗ ។

អឿន ៖ បាទ! ហ្នឹងហើយ ចុះមកពីពាមឯកមកក្រោមបេះមក គេហៅព្រៃស្តោ ។

ដានី ៖ ចឹងដល់ពេលនឹងទៅ ពូអត់ទៅតាមគាត់ទៀតទេ?

អឿន ៖ អត់ទេ គាត់ឲ្យខ្ញុំមកនៅនឹង ។

ដានី ៖ ឲ្យមកនៅកងចល័តនៅណាវិញ?

អឿន ៖ នៅវាលទ្រាលនឹង ។

ដានី ៖ ដែលកងចល័តជាមួយគេដែលថា គាត់ធ្លាប់ក្តាប់១០០០នាក់?

អឿន ៖ បាទ!

ដានី ៖ កាលនឹងពូរៀងធំនៅ?

អឿន ៖ ធំហើយ ខ្ញុំធំដែរហើយ ។

ដានី ៖ ដល់ពេលមកនៅកងចល័តនឹងពូធ្វើអីទៅ?

អឿន ៖ ធ្វើដូចគេដូចឯងដែរ ជីកប្រឡាយ ធ្វើស្រែដូចតែគ្នា ។

ដានី ៖ ធ្វើការហត់អត់បើប្រៀបធៀបទៅនឹងកងចល័ត?

អឿន ៖ បាទ! ហត់ ។

ដានី ៈ កាលពីមុនមកនៅផ្ទះជាមួយគាត់អត់ដែលធ្វើការ?

អឿន ៈ បាទ!

ដានី ៈ ចឹងដល់ពេលមកនៅកងចល័តទៅ យើងធ្វើការអី ៗ ចុះហូបចុកអីម៉េចទៅ?

អឿន ៈ ទេ! ហូបចុកធម្មតាដែរ កាលនឹងវា យើងចង់និយាយថាកាលនឹងខែប្រាំងដែលយើងកំពុងប្រមូលផល ហើយយើងនៅចេះវាមិនលំបាកទេការហូបចុក ។

ដានី ៈ ដល់ពេលខែវស្សា?

អឿន ៈ ខែវស្សាបាននឹងបានយ៉ាប់តិច ។

ដានី ៈ ហូបអីទៅ?

អឿន ៈ ហូបបបរដែរ ថាហូបឆ្អែតៗមិនបាច់ដល់យ៉ាប់ពិបាកក្រពះ ។

ដានី ៈ ហូបឆ្អែតៗ?

អឿន ៈ បាទ!

ដានី ៈ ចុះកាលនឹងដូចថានៅក្នុងកងចល័ត អ្នកនៅក្នុងស្រុកភូមិនឹង ឬក៏អ្នកមកពីចំងាយៗ?

អឿន ៈ អ្នកមកពីចំងាយ មកខាងនិរតី កាលនឹងខាងនិរតី ខាងតាកែវ ខាងកំពតអីគេមកក្តាប់ ។

ដានី ៈ គេមកក្តោបក្តាប់?

អឿន ៈ បាទ!

ដានី ៈ ចុះក្រែងឪពុកមាពូ គាត់ជាអ្នកក្តោបក្តាប់?

អឿន ៈ ចុះគេឲ្យគាត់ទៅធ្វើការផ្សារឃុំបាត់ហើយ ។

ដានី ៈ ចឹងពួកតាកែវ កំពត មកក្តោបក្តាប់វិញ?

អឿន ៈ បាទ!

ដានី ៈ ចុះពួកមកខាងតាកែវ មកកំពតមកក្តោបក្តាប់គាត់ម៉េចដែរ ក្តាប់ស្រួល ហើយក៏ពិបាក?

អឿន ៈ ហ៊ើ! មានកន្លែងខ្លះលំបាក មានកន្លែងខ្លះស្រួលដែរនឹង ។

ដានី ៈ ចុះកន្លែងពូ?

អឿន ៈ កន្លែងខ្ញុំវាមិនអីទេ វាធម្មតា វាចុះបើមានខាងក្រោមៗនឹងសុទ្ធតែពួកយើងនៅនឹងដែរ ។

ដានី ៈ គេអត់មានចាប់ យកទៅសម្លាប់ចោលទេ?

អឿន ៈ ទេ! វាមានខ្លះ ប៉ុន្តែគ្រាន់ថាយើងក៏មិនបានតាមដានវាក្នុងព្រឹត្តិការណ៍នឹង យើងព្រឹកឡើងយើងទៅធ្វើការ ល្ងាចឡើងយើងចូលកន្លែងវិញមក ។

ដានី ៈ ចុះម៉េចបានគេដកឪពុកពូយកទៅឃុំ ហើយបានគេយកពួកនិរតី ពួកកំពតអីមក?

អឿន ៖ ចឹងសម័យនឹងចឹងឯង តែគេចង់បំបាត់ពួកពាយ័ព្យចេញយកពួកនឹងមកក្តោបក្តាប់មក ចឹងដកពួកពាយ័ព្យឲ្យទៅកាន់នៅខាងឃុំ ភូមិអីវិញចឹង ។ ដើម្បីកុំឲ្យវាមានបញ្ហា ជួនកាលខ្លះវាមិនចឹង ចាប់យកទៅសម្លាប់ក៏មាន ។

ដានី ៖ អូ! ចាប់យកទៅសម្លាប់ទៀត ចុះឪពុកមាពូសព្វថ្ងៃនៅរស់នៅទេ?

អឿន ៖ នៅរស់ ។

ដានី ៖ គាត់នៅណាទៅ ឥឡូវនឹង ។

អឿន ៖ គាត់នៅព្រៃទទឹង គោកដូង ។

ដានី ៖ នៅណានៅព្រៃទទឹង គោកដូង?

អឿន ៖ បាទ! ព្រៃទទឹង គោកដូង វត្តឯកនេះ ស្គាល់ទេ អាដ្ឋូវចុះពីក្បាលខ្មោចមក ។

ដានី ៖ នៅភូមិព្រៃទទឹង?

អឿន ៖ បាទ! ព្រៃទទឹង ។

ដានី ៖ ព្រៃទទឹង ឃុំអី ឃុំគោកដូង?

អឿន ៖ អឺ! ខ្ញុំអត់ដឹងឃុំអីទេ ខ្ញុំបែកមកយូរហើយ ខ្ញុំមិនដឹងឃុំអីទេ ប៉ុនភូមិដឹងថាភូមិព្រៃទទឹង ។

ដានី ៖ នៅក្បែរក្បាលខ្មោចដែរ?

អឿន ៖ បាទ!

ដានី ៖ ក្នុងស្រុកថ្មគោលនឹង?

អឿន ៖ ខ្ញុំអត់ដឹងដែរ ដល់ខ្ញុំវាមិនដឹងជាគាត់ស្រុកថ្មគោល កាត់ពីស្រុកបាត់ដំបងមក ពីត្រឹមណាអីត្រឹមណា ខ្ញុំអត់ទាន់ដឹង ។ តែពីដើមដឹងថាខេត្តបាត់ដំបង ស្រុកបាត់ដំបង ម្ដុំអស់នឹង ។

ដានី ៖ តែកាលនឹងគាត់មានប្រពន្ធហើយ ប៉ុន្តែគាត់អត់នៅជាមួយគ្នាទេ?

អឿន ៖ បាទ! ចុះសម័យនោះម៉េចគេឲ្យយើងនៅជាមួយគ្នា មានប្រពន្ធមានអីក៏ដោយគឺយើងអត់មាននៅជាមួយគ្នាបានទេ ។

ដានី ៖ ប្រពន្ធគាត់អ្នកនៅក្នុង?

អឿន ៖ បាទ! នៅក្នុងនឹងដែរ ។

ដានី ៖ នៅភូមិជាមួយពូ ស្រុកកំណើតពូដែរ អត់ទេ?

អឿន ៖ អត់ទេ គាត់នៅព្រៃទទឹងនឹងម៉ង ។

ដានី ៖ ប្រពន្ធគាត់នៅព្រៃទទឹង?

អឿន ៖ បាទ!

ដានី ៖ គាត់មានកូនចៅទេ?

អឿន ៖ កូនចៅគាត់ មានតើ ខ្ញុំមិនដឹងថាមានប៉ុន្មានទេ ប្រហែលជា៤ក៏មិនដឹង ៥ក៏មិនដឹង ខ្ញុំក៏មិន បានដឹងដែរ ព្រោះខ្ញុំបែកមកវាយូរឆ្នាំដែរ ។

ដានី ៖ កាលពីសម័យនោះ គាត់ធ្លាប់ជួយគេជួយអីដែរអត់?

អឿន ៖ បាទ! ជួយ ។

ដានី ៖ ជួយម៉េចខ្លះ?

អឿន ៖ បាទ! គាត់ជួយត្រង់ថា អ្នកណាដែលគេត្រូវថា អឺ!សម័យនឹងគេតែនិយាយថា បើអ្នកណាមានកំហុសអី ចង់យកទៅសម្លាប់យកទៅអី គាត់អាចជួយខ្លះបានដែរ ។

ដានី ៖ គាត់បានជួយដែរ?

អឿន ៖ បាទ! ជួយដើម្បីឲ្យមនុស្សនឹងវាគ្រាន់ថាជាប់ទោសតិចតួច កុំឲ្យដល់ថ្នាក់ដល់សម្លាប់ដល់អី ។

ដានី ៖ បាទ! គ្រាន់ដូចថាជួយសម្រាល?

អឿន ៖ បាទ! ជួយសម្រាល ដើម្បីកុំឲ្យ ។

ដានី ៖ គាត់ឥឡូវ គាត់ឈ្មោះជួន ដដែល?

អឿន ៖ បាទ!

ដានី ៖ ប្រពន្ធគាត់?

អឿន ៖ ប្រពន្ធគាត់ឈ្មោះ រ៉េត ។

ដានី ៖ គាត់ចាស់ ហើយនៅក្មេង?

អឿន ៖ ចាស់ៗហើយ សក់ស្កូវហើយ ។

ដានី ៖ អាយុប្រហែលប៉ុន្មាន?

អឿន ៖ មិនដឹងជាប៉ុន្មាន អាច៥៦ ៥៧អី ។

ដានី ៖ ពូដែលជួបគាត់ទេ?

អឿន ៖ ជួប ខ្ញុំធ្លាប់ទៅលេងដែរនឹង ប៉ុនគ្រាន់ថាឥឡូវខ្ញុំដាច់ខានទៅលេងប្រហែលជាម៉ាឆ្នាំដែរហើយ ខ្ញុំមិនដែលបានទៅជួបគាត់ ។

ដានី ៖ ចឹងកាលជំនាន់នឹង ឧបមាថាពួកនិរតីមកគ្រប់គ្រង អ្នកពាយ័ព្យម៉ាចំនួនគេសម្លាប់ទៅ?

អឿន ៖ បាទ! អ្នកខ្លះគេយកទៅសម្លាប់ អ្នកខ្លះគេដកឲ្យទៅនៅកន្លែងឃុំ កន្លែងភូមិអីចឹង?

ដានី ៖ បាទ!

អឿន ៖ ដល់ពេលឪពុកមាពូគេផ្លាស់ឲ្យទៅនៅឃុំស្អីម៉េច ឃុំ?

ដានី ៖ ឃុំព្រៃស្តោ?

អឿន ៖ បាទ!

ដានី ៖ ឲ្យគាត់កាន់នៅឃុំព្រៃស្តោររហូតដល់ពេលណា?

អឿន ៖ រហូតដល់យួនចូល ខ្ញុំក៏បែកគាត់តាំងពីនេះមក ខ្ញុំក៏មិនដែលបានទៅជិតគាត់ដែរ ។

ដានី ៖ គាត់អត់មានរត់អី ពេលយួនចូលមក គាត់អត់មានរត់មកខាងនេះ?

អឿន ៖ អត់ទេ គាត់មិនដឹងថាគាត់ទៅណាទៅណែ ខ្ញុំកាលនឹងប្រហែលជាគាត់អត់រត់ទេ គាត់អាចនៅនឹង គាត់មិនរត់ទៅណាផង ។

ដានី ៖ គាត់អត់រត់ទៅណាទេ?

អឿន ៖ បាទ! មានតែខ្ញុំទេ ដែលរត់ ។

ដានី ៖ ចុះពូមកនៅកងចល័ត គាត់ឲ្យមកនៅជាមួយកងចល័តនៅវាលទ្រានឹង នៅបានរយៈពេលប៉ុន្មានទៅ?

អឿន ៖ ខ្ញុំនៅបានកន្លះឆ្នាំ ។ ខ្ញុំក៏ចេញពីវាលទ្រានឹងមកនៅអូរសង្កែ ការពិតវាជិតៗគ្នានឹង អូរសង្កែ យើងប៉ោយសំរោង នឹង ។

ដានី ៖ ចុះម៉េចពូអាចចេញបាន បើយើងនៅចល័ត?

អឿន ៖ ទេ! កាលនឹងខ្ញុំវាដូចថាវាមានលេខល្អដែរនឹង ខ្ញុំចេញមកបាន ។

ដានី ៖ យើងសុំគេចេញ ឬក៏?

អឿន ៖ អត់ទេ អត់សុំ ខ្ញុំចេញមកខ្លួនឯង ។

ដានី ៖ ចេញមកខ្លួនឯង?

អឿន ៖ បាទ! ចេញពេលយប់ ។

ដានី ៖ ចេញពេលយប់?

អឿន ៖ បាទ!

ដានី ៖ គេអត់តាមរកពូ?

អឿន ៖ អត់ទេ ។

ដានី ៖ គេអត់តឹងតែងអីប៉ុន្មានទេ?

អឿន ៖ ទេ! វាខ្លះតឹងតែងដែរ ខ្លះវាមានគេធ្វើឲ្យតឹងតែងៗ ខ្លះធ្វើទៅវាមិនសូវតឹងតែងជាមួយយើង ក៏វាស្រួលដែរ ។ ចឹងបានថាវាសម័យនឹងវាលំបាកណាស់ ។

ដានី ៖ ចឹងបានកន្លះឆ្នាំពូមកនៅអូរសង្កែវិញ?

អឿន ៖ បាទ!

ដានី ៖ នៅអូរសង្កែនៅជាមួយពីណា?

អឿន ៖ នៅកងចល័តដដែលនឹង ។

ដានី ៖ មកកងចល័ត ចុះមកកងចល័តនៅអូរសង្កែ គេទទួលពូឲ្យចូលដែរ?

អឿន ៖ បាទ! តែបងប្រុសខ្ញុំមួយគាត់នៅនឹង បានបងប្រុសនៅនឹង ។

ដានី ៖ បងប្រុសពូ គាត់ធ្វើប្រធាននៅនឹង?

អឿន ៖ តែគាត់មិនធ្វើប្រធានធ្វើអី តែគ្រាន់ថា កាលនឹងគាត់អាចនិយាយបានដែរ ។

ដានី ៖ គាត់មានតួនាទីនៅក្នុងជួរប្រធាននឹងដែរ?

អឿន ៖ បាទ!

ដានី ៖ ទៅចល័តអូរសង្កែនឹង ចល័តរបស់ឃុំស្រុក ឬក៏ភូមិភាគអី?

អឿន ៖ អឺ! ចល័តនឹង ចល័តភូមិភាគទាំងអស់ ម្តុំអូរសង្កែ ម្តុំអីនឹង ។

ដានី ៖ ចឹងពេលពូមកនៅខាងអូរសង្កែនឹង យើងមកនៅក្នុងកងចល័តដដែល ក៏នៅជាមួយឪពុកម្តាយ?

អឿន ៖ បាទ! នៅកងចល័ត ។

ដានី ៖ នៅកងចល័ត?

អឿន ៖ បាទ!

ដានី ៖ ធ្វើអីខ្លះទៅ នៅកងចល័ត?

អឿន ៖ មានធ្វើអីដូចខ្ញុំនិយាយពីខាងដើមចឹងថា មានធ្វើអីក្រៅពីការងារអស់នឹងទេ ជីកទំនប់ ជីកប្រឡាយ ធ្វើស្រូវធ្វើអីនឹង ។

ដានី ៖ ហើយហូបចុកអី?

អឿន ៖ ហូបចុកគ្រប់គ្រាន់ មកកន្លែងនឹងហូបចុកគ្រប់គ្រាន់ ។

ដានី ៖ តែបានជួបមុខឪពុកម្តាយអីដែរអត់?

អឿន ៖ តែខ្ញុំចង់ទៅលេងទៅបាន កាលនឹងឪពុកម្តាយខ្ញុំនៅជិតនឹងដែរ គាត់នៅថ្នល់រទេះភ្លើង ខ្ញុំនៅខាងក្រោមថ្នល់រទេះភ្លើង ទៅខាងលិចថ្នល់រទេះភ្លើងតិចទៅ ពេលខ្ញុំចង់ទៅលេងមក ។

ដានី ៖ គេអត់មានថាអី គេអត់មានឃាត់យើងទេ?

អឿន ៖ បាទ!

ដានី ៖ កាលនឹងនៅស្រុកអីគេ កន្លែងអូរសង្កែ វាលទ្រា?

អឿន ៖ កាលនឹងមានក្រៅអីស្រុកបាត់ដំបង មានស្រុកបាត់ដំបងមួយនឹងឯងនៅម្តុំអស់នឹង ។

ដានី ៖ កាលនឹងគណៈស្រុកឈ្មោះអីទៅ?

អឿន ៖ គណៈស្រុក ខ្ញុំវាភ្លេចអស់ដែរហើយ ព្រោះគេចាប់យកទៅអស់ទៅ ។

ដានី ៖ បាទ! គេចាប់យកទៅ ។ ចឹងពូនៅអូរសង្កែនឹងរហូតដល់បែក៧៩បណ្តោយ?

អឿន ៖ បាទ!

ដានី ៖ ពេលយួនចូលឆ្នាំ៧៩យ៉ាងម៉េច បានពូរត់ ម៉េចបានពូរត់មក?

អឿន ៖ ចុះបើមិនដឹងថាទៅណា វានឹកឃើញថា ចូលទៅខាងក្នុងថាយួនហើយ យើងចូលទៅទៀតដូចពិបាក សម្រេចចិត្តថានាំគ្នារត់មកនេះមក ។

ដានី ៖ ចុះអឺ! ឪពុកម្តាយពូគាត់មកជាមួយ រត់មកដែរ?

អឿន ៖ អត់ទេ ឪពុកម្តាយខ្ញុំទៅរកស្រុកភូមិកំណើតគាត់វិញទៅ ។

ដានី ៖ ចុះម៉េចបានពូអត់រត់ទៅរកឪពុកម្តាយ?

អឿន ៖ ចឹងបានខ្ញុំចង់និយាយដូចខាងដើមចឹងថា កាលនឹងវាចេះតែជ្រួលច្របល់តាមគ្នា មនុស្សកំពុងសភាពការណ៍តានតឹងចឹងទៅ
បំផុសបំផុលតាមគ្នាទៅធ្វើឲ្យយើងចេះរត់មកតាមគេដែរ ទៅ ។

ដានី ៖ កាលនឹងគេបំផុសបំផុលថាម៉េចទៅ?

អឿន ៖ គេថាកាលណាបើយើងចូលទៅក្នុង អាចយួនអារ-កអាអីធាងត្នោតអីចឹងទៅណា ។ យើងនឹកឃើញពីអតីត សម័យដើមណាចាស់ៗតែងតែនិយាយថា យួនដាំក្បាលតែអ៊ុងអីណា យើងចេះតែវិភាគតាមនឹងទៅ ដូចថាវាត្រូវរបស់គេ យើងក៏តាមគេ ។

ដានី ៖ វិភាគទៅ ឃើញចឹង?

អឿន ៖ បាទ!

ដានី ៖ អ្នកណាដែលគេអ្នកបំផុសបំផុលចឹង?

អឿន ៖ ទេ បើនិយាយទៅនៅម៉ាកងចល័ត នៅម្តុំអស់នឹងគឺវាទូទៅចឹងម៉ង វាដូចថាវាផ្អើលម៉ាឆុលចឹងទៅ នាំគ្នាចេះមកៗ ។

ដានី ៖ នាំគ្នាមកទៅ?

អឿន ៖ បាទ! មករហូតមកដល់ធ្លាក់មកដល់ព្រំដែន ធ្លាក់មកដល់ព្រៃហិតព្រៃហោងចឹងទៅដល់ចឹង មិនដឹងថារកផ្លូវទៅវិញមិនឃើញ ។ ហើយម្យ៉ាងចូលដល់ក្នុងអន្តភាពហើយ

គេបេះតែផ្ទើ　　　　　　　　　　　　　　　　នយោបាយយើងម១-២អី

ដើម្បីកុំឲ្យយើងចាកចេញទៅរកឪពុកម្ដាយវិញ យើងបេះតែ នឹកឃើញដល់វែងឆ្ងាយទៅ យើងមិនទៅណា បេះនាំគ្នានៅជុំគ្នាចឹងទៅ ។

ដានី : ចឹងពូរត់មកព្រៃ ដំបូងរត់ទៅខាងណា ទៅនៅក្នុងអន្លង់ភាពណាខ្លះទៅ?

អឿន : ខ្ញុំវាភ្លេចអស់ហើយពីរឿងអន្លង់ភាព ខ្ញុំរត់មកដំបូងខ្ញុំនៅអន្លង់ភាពស្រុកទេគេហៅកងកម្លាំង ។

ដានី : ស្រុកអីគេ?

អឿន : ស្រុកអឹ! ស្រុកយើងបវេលនេះឯង ។

ដានី : ស្រុកបវេល?

អឿន : បាទ! ដល់នៅនឹងទៅខាងភូមិភាគនេះគេខ្វះកម្លាំង គេយកកម្លាំងពួកខ្ញុំនេះទេជាមួយគេទៅត្រៀមនៅ ។

ដានី : ភូមិភាគណា?

អឿន : ខាងភូមិភាគ ខាងកងកម្លាំងភូមិភាគគេម៉ង ខ្ញុំវាមិនដឹងភូមិភាគគេណា អត់ចាំ អន្លង់ភាពកាលនឹង ។

ដានី : អត់ដឹងគេហៅភូមិភាគអី ភូមិភាគពាយ័ព្យ ហើយមិនមែន?

អឿន : បាទ! មិនមែនទេ កាលនឹងវាចំរុះមកហើយ វាលែងមានពាយ័ព្យ លែងមាននិរតី លែងមានបស្ចឹម បូព៌ាអីអត់ហើយ នឹងដល់ចឹងចេញមកគេហៅកងកម្លាំងភូមិភាគ កងកម្លាំងភាគ ។

ដានី : ភាគណា ភាគនឹងមកនៅណាទៅ?

អឿន : នៅកាលរត់ដំបូងមកនៅម្ដុំយើងភូមិថ្មីថ្មគោលនេះដែរនឹង
កាលនឹងយើងនៅវៃគ្នាម្ដុំអស់នេះ ទាំងអស់ កងកម្លាំងភូមិថ្មី ថ្មគោលសែនត្រែងយើងនេះ ។

ដានី : បាទ! សែងត្រែង?

អឿន : បាទ! ដល់នៅបានប្រហែលជា២ខែ៣ខែ ដល់យួនបុកខ្លាំងមកនាំគ្នារត់មកបែកបាក់គ្នា ខ្លះក៏ទៅនេះខ្លះទៅនោះ បែកកម្លាំងគ្នាបែកបាក់គ្នាអស់ទៅ ។ ពួកខ្ញុំបានមករស់នៅក្នុងអន្លង់ភាព៩០៥ ។

ដានី : អន្លង់ភាព៩០៥?

អឿន : បាទ!

ដានី ៖ នឹងអង្គភាព៩០៥ កងពល?

អឿន ៖ អត់ទេ វរសេនាធំ ។

ដានី ៖ វរសេនាធំ៩០៥?

អឿន ៖ បាទ! តែកងពល៣២០ ។

ដានី ៖ កងពល៣២០?

អឿន ៖ បាទ!

ដានី ៖ នៅណាកន្លែងនឹង?

អឿន ៖ នៅម្តុំនឹងម៉ង ។

ដានី ៖ អូ! រត់ពីភូមិថ្មីមកដល់នឹងហើយ?

អឿន ៖ បាទ!

ដានី ៖ ឆ្នាំណាអានឹង?

អឿន ៖ អានឹងយើងឆ្នាំ៧៩ហើយ ខ្ញុំនៅ មើលលើកទី១ខ្ញុំនៅខ្មែរ នៅអូរអន្លក់យើង បាទ!ខ្ញុំចេញពីនឹងមក ខ្ញុំមកនៅដើមខ្នុរៗរហូតដល់ឃ្មួនអុកឡុកខ្លាំង ខ្ញុំនៅម្តុំចក្រីនៅអីនឹង ។ បើនិយាយទៅតំបន់នេះខ្ញុំដើរពេញទាំងអស់នឹង ។

ដានី ៖ ចុះឆ្នាំ៧៩ដដែល?

អឿន ៖ បាទ!

ដានី ៖ ៧៩ កាលនឹងគេហៅកងពល៣២០?

អឿន ៖ បាទ!

ដានី ៖ កងពល៣២០ ដល់ពេលវរៈពូវរៈ៩០៥?

អឿន ៖ បាទ!

ដានី ៖ ៩០៥ វរៈឈរជើងនៅណា?

អឿន ៖ ឈរជើងនៅយើងម្តុំនេះឯង ៥៣ ម្តុំតាង៉ុក កាលនឹងគេហៅតាង៉ុក ។

ដានី ៖ តាង៉ុក?

អឿន ៖ បាទ! ម្តុំចក្រីអីនេះ ពួកខ្ញុំនៅនេះ ។

ដានី ៖ ពូមានតួនាទីអីដែរ?

អឿន ៖ ខ្ញុំអត់មានតួនាទីអីទេ ខ្ញុំគ្រាន់ថាកងកម្លាំងយុទ្ធជនដែរនឹង ។

ដានី ៖ កាលនឹងប្រធានកងពល៣២០ពីណា?

អឿន ៖ តាកន ។

ដានី ៖ តាកន នី កន?

អឿន ៖ បាទ! លោក នី កន ។

ដានី ៖ ចុះប្រធានវរៈរបស់ពូ?

អឿន ៖ គង់ បៃ ។

ដានី ៖ គង់ បៃនឹងគាត់ប្រធានវរសេនាធំរបស់ពូ?

អឿន ៖ បាទ!

ដានី ៖ ៩០៥?

អឿន ៖ បាទៗ ។

ដានី ៖ ខ្ញុំទើបជួបគាត់មិញ?

អឿន ៖ ចឹង ។

ដានី ៖ អត់ដឹងៗថាគាត់ប្រធានវរៈ?

អឿន ៖ បាទ!

ដានី ៖ ចុះគណៈស្រុក?

អឿន ៖ គណៈស្រុក រាល់ថ្ងៃ គណៈស្រុករាល់ថ្ងៃនេះ?

ដានី ៖ បាទ!

អឿន ៖ ពីដើមគាត់ឈរខាងគណៈស្រុកនេះឯង គង់ បៃ ប៉ុនដល់ឥឡូវគាត់ផ្ទេរឲ្យគេ ឲ្យតាគឿន អីគឿនទេ ខ្ញុំវាភ្លេចឈ្មោះ ។

ដានី ៖ តាគឿន គាត់ធ្វើអីដែរកាលជំនាន់នោះ?

អឿន ៖ ទេ! ខ្ញុំអត់ដែលជួបតាគឿន ខ្ញុំអត់ដែលជួបទេ ។

ដានី ៖ ចុះក្នុងគណៈកងពល៣២០ មានតាកន គាត់ប្រធាន?

អឿន ៖ បាទ!

ដានី ៖ បន្ទាប់ៗគាត់?

អឿន ៖ ខ្ញុំក៏ភ្លេចមិនបានដែលកាលនឹងស្គាល់ច្បាស់តែគាត់ម៉ង ។

ដានី ៖ ស្គាល់តែតាកន?

អឿន ៖ បាទ! ព្រោះកាលរហូតមកដែលខ្ញុំរស់នៅ ខ្ញុំធ្លាប់ទៅប្រជុំជាមួយគាត់នៅនឹងតែក្រៅពីនឹង បើនិយាយទៅកាលពីសម័យនឹង

ចង់និយាយថាគាត់ក្តាប់សមរភូមិខាងត្បូងស៊ីសាផុន ។ កាលនឹងចង់និយាយថា ខាងត្បូងស៊ីសាផុននេះ មានតែគាត់ ។

ដានី : មានតាកន?

អឿន : បាទ!

ដានី : ខាងត្បូងស៊ីសាផុនចាប់ពីត្រឹមណាមក?

អឿន : ចាប់ពីអឺ! ផ្លូវជ្រោយប៉ែតមក ។

ដានី : ចាប់ពីផ្លូវជ្រោយប៉ែតមក?

អឿន : បាទ! អានឹងគេហៅសមរភូមិខាងត្បូងស៊ីសាផុន ។

ដានី : មានម៉ាឡៃ មានអី?

អឿន : បាទៗ ។

ដានី : ហូរហែលមក មានតាកន គាត់អ្នកក្តាប់ទាំងអស់?

អឿន : បាទ! គាត់ក្តាប់រួមម៉ាចំហៀង ។

ដានី : ចុះមានច្រើនកងពល?

អឿន : បាទ! មានច្រើន កងពលតូច ។

ដានី : ចុះនៅកន្លែងយើងនឹង មុំនឹងខាងភ្នំព្រឹក ហៅកងពលអីគេ?

អឿន : កងពល៣២០នឹងឯង ។

ដានី : ចុះមុំខាងម៉ាឡៃខាងអីវិញ?

អឿន : ខាងម៉ាឡៃ អឺ!មិនដឹងថាកងពលអី ខ្ញុំក៏អត់ដែលបានតាមដានដែរ ព្រោះកាលនឹងវាខ្ជិល យកចិត្តទុកដាក់អារឿងចឹងៗ ។

ដានី : បាទ! ចឹង៣២០នឹងទាំងកំរៀង ទាំងភ្នំព្រឹក្ស ទាំងសំពៅលូន ៣២០ មួយទេ?

អឿន : អត់ទេ កំរៀងនោះផ្សេង ។

ដានី : កំរៀង កងពលប៉ុន្មានទៅ?

អឿន : អឺ! កំរៀងនោះ ខ្ញុំភ្លេចអស់ហើយ ខ្ញុំវាអស់សួរយកចិត្តទុកដាក់កត់ត្រាទុក ។

ដានី : បាទ! ចុះនៅនេះភ្នំព្រឹក្សយើង?

អឿន : ភ្នំព្រឹក្សនេះឯង មានភ្នំព្រឹក្ស៣២០ ។

ដានី : មានភ្នំព្រឹក្សទេ ៣២០?

អឿន : បាទ! ចាប់ពីសាស្តាមក ។

ដានី ៖ ចុះសំពៅលូន?

អឿន ៖ សំពៅលូនទៅខាងនោះ កងពលគេផ្សេង ។

ដានី ៖ កងពលប៉ុន្មានទៅ?

អឿន ៖ ខ្ញុំភ្លេចអស់ ខ្ញុំអត់បាន ដូច១៩ទេដឹង អាចជា១៩ ។

ដានី ៖ ចឹងពូនៅក្នុងវរៈសេនាធំ៩០៥របស់តាប៉ៃ?

អឿន ៖ បាទ!

ដានី ៖ ចឹងម៉េចទៅដល់ពេលពូនៅក្នុងវរៈនឹង ពូឈរជើងនៅនឹងរហូតក៏មានការផ្លាស់ប្តូរ?

អឿន ៖ អត់ទេ អត់មានការផ្លាស់ប្តូរគ្រាន់ថា ឧទាហរណ៍ថាបើយើងចង់ឆ្លងកាត់ថ្នល់ជាតិលេខ៥អី ចឹង ចង់ឆ្លងកាត់ទៅណា ឬដឹកជញ្ជូនអីទៅណា យើងឆ្លងផ្លូវនេះអត់រួច យើងអាចចល័ត ទៅឆ្លងនៅខាងយើងម្តុំលាចខាងនោះទៅ ។ ម្តុំគេហៅសមរភូមិលាចខាងលិច ទៅម្តុំស្ពានតា ម្តុំតាគោកអីនឹង ខ្ញុំឆ្លងកាត់ទៅនឹងដែរ ។ ហើយបើទៅនឹងមិនរួច អាចទៅនឹងទៅខាងម្តុំ ម៉ាឡៃអីចឹងទៅៗនឹងដែរ ព្រោះខ្ញុំវាបាននៅកងទ័ពវាពិបាកថា ចង់និយាយថាសមរភូមិវា អត់ទៀងទាត់ណា ។ បាទ! អត់ទៀងទាត់ទេ ព្រោះត្រូវទាញពួកខ្ញុំយកទៅដាក់ណា ទាញ ទៅចឹងទៅ នៅខាងទន្លេសាបអីចឹងទៅ ។ ចឹងបានថាកំណត់អត់បាន ។

ដានី ៖ កាលនឹងយួនមានដែលវាចូលមកដល់នេះទេ?

អឿន ៖ បាទ! យើងកាលពីឆ្នាំ៨៥វាមកដល់ដែរ ប៉ុនដល់៨៥ខាងខ្ញុំនេះ វាបំពាស់ខ្លាំងទៅ យួន ដកចេញអស់ទៅ នៅសល់តែទាហានខាងក្នុង ដល់នៅទាហានខាងក្នុងពួកខ្ញុំវាបែកបាក់អស់ ទៅ បានពួកខ្ញុំមកនៅនេះ ។

ដានី ៖ ចឹងកាលឆ្នាំ៨៥យួនវាចូលមកនឹង យើងទៅណាទៅ?

អឿន ៖ នៅដីថៃ ។

ដានី ៖ ទៅនៅដីថៃ?

អឿន ៖ បាទ! ចូលទៅនៅដីថៃ កសាងជំរំមួយគេហៅជំរំសាយអេច ដាក់ប្រជាពលរដ្ឋដកចេញពី ភូមិដែលធ្លាប់នៅម្តុំចក្រី ដូចម្តុំសំពៅលូនអីនឹង ។ ដកយកមកដាក់នៅជំរំសាយអេច ។

ដានី ៖ ចឹងដល់ពេលដកទៅយួននៅនឹង?

អឿន ៖ បាទ! យួននៅលើភ្នំ នៅម្តុំត្រង់នេះ ។

ដានី ៖ នៅបានយូរដែរ យួន?

អឿន ៖ នៅយូរដែរ នៅរហូតដល់ឆ្នាំ៩៦ អឺ!រហូតដល់ឆ្នាំ៩២ ។

ដានី ៖ យួនដកចេញ?

អឿន ៖ បាទ! ៩១ ៩២នឹងបានយួនដកចេញអស់ទៅ ។

ដានី ៖ យួនដកចេញ នៅសល់ទាហានខាងក្នុង?

អឿន ៖ បាទ! នៅទាហានរដ្ឋាភិបាលខាងក្នុង ពួកខ្ញុំវ៉ៃចឹងទៅ បាក់អស់ទៅ បានពួកខ្ញុំឡើងមកនៅតាមម្តុំអស់នេះ តែដកចេញពីថៃមក អត់ទាន់បានមកនៅបណ្តោយនេះទេ នៅក្នុងនោះ នៅជាប់ព្រំដែននោះដែរ ។

ដានី ៖ ខាងនោះ ម៉េចបានអត់ទាន់បានមកនៅនេះ?

អឿន ៖ កាលនឹង ចុះយើងម្តុំអស់នេះ អត់មានទឹក ។ កាលពីនៅព្រៃឈើច្រើន ទឹកអត់មានទេតាមនេះ ។

ដានី ៖ ចុះមានមីនមានអីដែរអត់?

អឿន ៖ មានៗ តែចង់មកនៅនឹងនាំគ្នាប្រើកម្លាំង៤-៥នាក់មកការមកដោះទៅ មកការកន្លែងទៅ យកកន្លែងនឹង ។

ដានី ៖ មីនខាងណា អ្នកដាក់?

អឿន ៖ ខាងពួកខ្ញុំនេះ ។

ដានី ៖ យួនមានដាក់ដែរ?

អឿន ៖ អត់ទេ យួនដាក់តែផ្លូវក-៥នឹង ។

ដានី ៖ ដាក់ផ្លូវក-៥?

អឿន ៖ ដាក់ផ្លូវក-៥ខាងកើតនេះតិច ។

ដានី ៖ នឹងដោះដែរ ឥឡូវ?

អឿន ៖ ដោះអស់ ពួកស៊ីម៉ាក់គេមកដោះ ។

ដានី ៖ ចុះកាលយួននៅលើនឹងគេវ៉ៃយកអត់បាន?

អឿន ៖ បាទ! គឺថាមិនត្រូវវ៉ៃផង នៅទល់មុខនេះ មិនដែលវ៉ៃផង ធ្លាប់វ៉ៃកាំភ្លើងធំដាក់តិចតួច ។

ដានី ៖ ចុះម៉េចឲ្យយួនវ៉ៃចូលបាន?

អឿន ៖ ចុះ មានកម្លាំងយើងតិច ។

ដានី ៖ កម្លាំងយើងតិច?

អឿន ៖ បាទ! កាលនោះកម្លាំងខាងពួកខ្ញុំនេះវាតិច កាលណាយួនបុកទ្រង់ទ្រាយធំចឹងទៅទប់មិនជាប់ ដកចេញទៅ ។

ដានី ៖ កម្លាំងយើងតិច?

អឿន ៖ បាទ!

ដានី ៖ យួនទីតាំងវាដាក់នៅលើនេះ លើភ្នំ?

អឿន ៖ បាទ!

ដានី ៖ ចុះពូត្រូវរបួស ត្រូវតាំងពីអន្លង់ ពិការជើង?

អឿន ៖ ខ្ញុំដាច់ជើងនេះ កាលពីយើងសមាហរណកម្មហើយ ។

ដានី ៖ សមាហរណកម្មហើយ?

អឿន ៖ បាទ!

ដានី ៖ យ៉ាងម៉េចអានឹង?

អឿន ៖ ខ្ញុំទៅអារឈើ ។

ដានី ៖ នៅនេះសមាហរណកម្មឆ្នាំណា?

អឿន ៖ ៩៦ ។

ដានី ៖ ម៉េចកាលសមាហរណកម្ម យើងយ៉ាងម៉េចបានសមាហរណកម្ម កាលពីឆ្នាំ៩៦?

អឿន ៖ អឺ! កាលពីសមាហរណកម្ម មានថ្នាក់ដឹកនាំនៅកន្លែងនេះក្បត់ ថ្នាក់ដឹកនាំខ្មែរក្រហម តានឹងគាត់មក គាត់នៅលើតាកននឹងទៀត ។

ដានី ៖ តាណា?

អឿន ៖ សុន សេន ។ ដល់មកគាត់មានផែនការណ៍ក្បត់ គាត់មកដល់កាលនឹងយើងជឿនលឿនដែរ ពួកខ្ញុំអីខ្លះគេមានទៅ គេទិញឡានជិះ ទិញម៉ូតូជិះ ទិញរទេះគោ អាត្រាក់ទ័រអី ។ ដល់សុន សេន គាត់មកដល់ ដកម៉ូតូ ដកម៉ាស៊ីនអារឈើ ដករទេះគោ ដកឡានដកអីទៅ ។ ដល់ចឹងស្ថានការណ៍បេះតានតឹងទៅៗ សូម្បីតែគ្រាប់កាំភ្លើងគ្រាប់អីក៏មិនសូវមានប្រើឲ្យគ្រប់គ្រាន់ ដល់ចឹងខាងអ៊ី ឈានៗ លោកខាងភាពនេះ នៅម៉ាឡៃ នៅប៉ៃលិន គាត់សម្រេចចិត្តថា គាត់ធ្វើៗនឹងមិនមែនចង់ឲ្យផ្ដាច់ទៅជាសមាហរណកម្មទេ គាត់ធ្វើនឹង គាត់ចង់ថាធ្វើនឹងធ្វើ ដើម្បីរំលំសុន សេន ឲ្យចេញ ។

ដានី ៖ សុន សេនគាត់ម៉េច?

អឿន ៖ គាត់ ផែនការគាត់ក្បត់ ចង់និយាយថាក្បត់ គាត់ចូលទៅខាងរាជរដ្ឋាភិបាលហើយ ។

ដានី ៖ គាត់ចូលទៅហើយ?

អឿន ៖ បាទ! តែខ្លួនប្រាណគាត់នៅៗតស៊ូជាមួយយើងទេ ប៉ុនគ្រាន់ជាគំនិតខួរក្បាលរបស់គាត់នឹង គាត់ទៅជាមួយរាជរដ្ឋាភិបាលហើយ ។

ដានី ៖ ប៉ុន្តែសុន សេន ហើយនឹងនី កន ក្រែងគាត់បងប្អូនគាត់?

អឿន ៖ បាទ! ថាបងប្អូន ប៉ុនខ្ញុំអត់យល់ដែរ ប៉ុនមើលមុខមាត់ខ្ញុំថាដូចមិនមែនបងប្អូន អាចជាបងប្អូនចិញ្ចឹម ក៏មិនដឹង ពិបាកសន្និដ្ឋានដែរ ព្រោះខ្ញុំធ្លាប់ៗនៅប្រជុំនៅនឹងកន្លះខែអីខ្ញុំសម្គាល់ មើលទៅ ខ្ញុំហាក់ដូចជាមិនមែនបងប្អូនបង្កើតទេ ព្រោះសុន សេន សាច់ឈាមគាត់ចិនចំ ម៉ង ៗ តែនី កន គាត់ចិនដែរ តែគ្រាន់ថាកំពស់កំពរសាច់ឈាមអីមើលទៅថាវាខុសគ្នា មុខមាត់ ។

ដានី ៖ តែគាត់ស្និតស្នាលជាមួយគ្នា?

អឿន ៖ បាទ! អត់ទេ មិនសូវស្និតស្នាលដែរ គាត់ហាក់បីដូចថា ម៉ាផ្នែកៗរបស់គាត់ចឹង ។ ពេលចូលទៅប្រជុំអីចឹងទៅ ដូនកាលលោក នី កននឹង គាត់មកម៉ាភ្លែតចឹងទៅក្រៅពីនឹងឲ្យសុន សេន គាត់ធ្វើទាំងអស់ចឹងទៅ ។

ដានី ៖ តែដល់ពេលក្រោយមក អឺ! នី កន ហើយតាសុន សេន គាត់ត្រូវគ្នា ក៏គាត់ឈ្លោះគ្នាមុនពេលសមាហរណកម្ម?

អឿន ៖ អឺ! គាត់អត់ឈ្លោះគ្នាទេ ត្រូវគ្នា តែពេលសមាហរណកម្មនឹង គាត់រត់ទៅជាមួយគ្នា ។ តែមិនដឹងគាត់ដល់ណា កាលនឹងប្រហែលជារត់ទៅនោះ ទៅខាងលិចកោះកុង ពួកកម្លាំងពួកខ្ញុំទៅតាមដល់នឹងដែរ ប៉ុនដល់ទៅប្រហែលជាគាត់ទម្លាក់លោក នី កន នឹងចោលត្រង់ណាមិនដឹង គាត់ទៅតែគាត់ ។

ដានី ៖ ចុះនី កន គាត់នៅណា?

អឿន ៖ គាត់នៅ៣២នេះ នៅអឺ!សំពៅលូន ។

ដានី ៖ សំពៅលូន?

អឿន ៖ បាទ!

ដានី ៖ គាត់ធ្វើអីឥឡូវ?

អឿន ៖ ទេ! អត់ដឹងថាគាត់ធ្វើអីដែរ ឥឡូវគាត់ក៏មិនសូវ ។

ដានី ៖ គាត់មានតួនាទីធំ មានមុខ មានមាត់?

អឿន ៖ ទេ! មានតាមក្តាប់ទៅថាគាត់មានដែរ ហ៊ុន សែន គាត់ឲ្យធ្វើដែរ តែគាត់អត់ធ្វើប្រហែលជាគាត់នឹកឃើញមិនធ្វើ គាត់ចាស់ហើយ គាត់ខ្ជិលគាត់ ។

ដានី :	អឺ! កាលនឹងឆ្នាំប៉ុន្មានដែលសុន សេន គាត់មក ហើយគាត់ដកយករបររបស់ ដូចម៉ូតូ សម្ភារៈ?

អឿន :	អឺ! កាលនឹងឆ្នាំយើង៩២នឹងឯង ។

ដានី :	៩២?

អឿន :	អ៊ើ!មុន៩២ អឺ! ៨៧ ៨៨ គាត់មកកាន់ក្តាប់នៅនេះ ។

ដានី :	កាន់កាប់ហើយគាត់ដក?

អឿន :	បាទ!

ដានី :	ដែលដូចពូអីអត់សប្បាយចិត្តទេ?

អឿន :	បាទ! ចុះមានអ្នកណាសប្បាយចិត្ត បើឃើញចឹង គាត់ដក គាត់មកដកយើងកាលពីយើងចចារក្រុងបារីសហើយទេ គាត់ធ្វើសកម្មភាពនឹង តែគាត់ក្តាប់ពីមុនមក គាត់អត់ទាន់ធ្វើអីទេ តែមកដល់យើងប៉ារីសហើយនេះ ។ ចុះកិច្ចព្រមព្រៀងនៅប៉ារីសហើយនេះ បានគាត់ចាប់ផ្តើមធ្វើសកម្មភាពដកតាំងម៉ូតូ ដកតាំងពីស៊ីម ដកតាំងពីរទេះគោ ត្រាក់ទ័រឡានទៅ ។

ដានី :	ដកទៅ គេប្រឆាំងគាត់ បះបោរប្រឆាំងគាត់ដែរ ហើយក៏អត់ទេ?

អឿន :	អត់ទេ ចេះតែនៅរហូតទៅឆ្នាំ៩៦ បានចាប់ផ្តើមមានសកម្មភាពបះបោរហើយ ។

ដានី :	ដល់ពេលមានសកម្មភាពបះបោរនឹង គាត់រត់ហើយ?

អឿន :	បាទ!

ដានី :	សុន សេន នឹ កនអីគាត់រត់ទៅទាំងពីរនាក់

អឿន :	បាទ! រត់ តែកាលនឹងវាដោយតាំងពីមេប៉ូលីស កាលនឹងមានគេរៀបចំប៉ូលីសដែរ ។

ដានី :	ពីណាខ្លះរត់ទៅ?

អឿន :	ដោយតាំងពីម៉េប៉ូលីស មេអីទៅជាមួយផង ។

ដានី :	ឈ្មោះអីគេខ្លះ?

អឿន :	តែមេប៉ូលីសនឹងស្លាប់ហើយ ។

ដានី :	ឈ្មោះអី?

អឿន :	ឈ្មោះ តាអ៊ិត ។

ដានី :	ចុះតាបែ មានទៅជាមួយ?

អឿន :	អត់ទេ បើនិយាយក្រៅពីនឹង អត់មានអ្នកណាទៅជាមួយគាត់ទេ ព្រោះគាត់ជ្រើសរើសយកទៅតែកូនចៅគាត់ បងប្អូនគាត់នឹង ។

ដានី ៖ យកទៅបងប្អូនគាត់ទៅទេ?

អឿន ៖ បាទ!

ដានី ៖ មានតែ?

អឿន ៖ មានតែនី កន, តាអ៊ិត ហើយកូនចៅគាត់ផ្សេងៗទៀត ខ្ញុំអត់ស្គាល់ ។

ដានី ៖ តាអ៊ិត កាលមុនគាត់ធ្វើមេប៉ូលីសនៅណា?

អឿន ៖ ប៉ូលីសនៅនឹងម៉ង នៅ យើងស្រុកភ្នំព្រឹក្សនឹង ។

ដានី ៖ ចឹងដល់ពេលឆ្នាំ៩៦ យើងធ្វើសមាហរណកម្ម ជាមួយអ៊ី ឈាន ជាមួយសុខ ភាពអីទាំងអស់គ្នា?

អឿន ៖ បាទ!

ដានី ៖ ចងពូពិការនេះក្រោយទេ?

អឿន ៖ បាទ!

ដានី ៖ ពេលពូទៅ?

អឿន ៖ បាទ!

ដានី ៖ ឆ្នាំណា ពូពិការឆ្នាំណា?

អឿន ៖ ៩៦នឹងដែរ តែវាចុងឆ្នាំហើយ វាចូលដល់ មើលកាលនឹងខែ៩ ថ្ងៃទី២០ប៉ុន្មានទេ ខ្ញុំដាច់ជើងថ្ងៃអាទិត្យដែរ ខ្ញុំអត់បានចាំ ។

ដានី ៖ អានេះយើងត្រូវយ៉ាងម៉េច យើងជាន់មីន ហើយក៏ម៉េច?

អឿន ៖ បាទ! ជាន់មីន ។

ដានី ៖ ជាន់មីនរបស់ខាងយើង ឬក៏មានរបស់?

អឿន ៖ បាទ! មីនខ្លួនយើង ។

ដានី ៖ យើងអត់ដឹង យើងដាក់ខ្លួនគេ យើងអត់ដឹងថាទីតាំងណាមានមីន?

អឿន ៖ បាទ! ដឹងតើ ប៉ុន្តែកាលនឹងយើងអារឈើ បេះរុកទៅ រកឈើ បេះរុក ឃើញឈើល្អបេះ កាប់ទៅ ដល់ថៃដន្សាពេលចំចឹង ។

ដានី ៖ ត្រូវតែពូម្នាក់ទេ?

អឿន ៖ បាទ! មីននឹងត្រូវម្នាក់ៗ អត់មានត្រូវពីណាទៀត ។

ដានី ៖ មីន៦៩?

អឿន ៖ អត់ទេ មីនស្គរ កន្ទ្រប ។

ដានី ៖ មីនកន្ដែប?

អឿន ៖ ប៉ុនៗនេះ ។

ដានី ៖ សុន សេន គាត់ស្លាប់នៅណា?

អឿន ៖ ទេ! ខ្ញុំនឹកឃើញថាមិនដឹងគាត់ស្លាប់ មិនដឹងថាគាត់រស់ផង បើតាមដឹងខ្ញុំវិភាគទៅមិនអាចស្លាប់ទេ ខ្ញុំថាសុន សេន មិនស្លាប់ ព្រោះខ្សែបណ្ដាញគាត់មួយខាងរាជរដ្ឋាភិបាល ។

ដានី ៖ ចុះម៉េចដឹងថាគាត់ចូលខ្សែបណ្ដាយជាមួយរាជរដ្ឋាភិបាល?

អឿន ៖ ចុះបើកាលនឹងធម្មតាយើងរត់ទៅដល់នោះហើយ ហេតុអីបានគាត់ទៅចេញនៅនោះវិញ ។ គាត់ទៅផ្លូវណាវិញ ចង់ដឹងថាគាត់ទៅផ្លូវណាវិញ ។ ពេលដល់សមាហរណកម្មចប់ហើយ ឮ ថាតាម៉ុកសម្លាប់ចោលនៅណា មិនដឹងពិតមិនពិត ។

ដានី ៖ ចុះតាម៉ុកម៉េចដែរតាម៉ុក គាត់អ្នកដឹកនាំ?

អឿន ៖ តាម៉ុក ខ្ញុំមិនដែលជួបប្រទះដែរ ព្រោះខ្ញុំមិនដែលទៅប្រឡូកជាមួយគាត់ដែរនឹង ខ្ញុំធ្លាប់នៅមុំអស់នេះ ខ្ញុំមិនអាចដឹងចរិតគាត់យ៉ាងណាៗ ។

ដានី ៖ ប៉ុន្ដែដូចថាកងទ័ព ដូចថាទាហានប្រជាជនអីនៅតំបន់យើង ចូលចិត្តគាត់ស្រឡាញ់គាត់ដែរ?

អឿន ៖ បាទ! មានអី នៅមុំអស់នេះ គ្មានអ្នកណាដឹងចរិតគាត់យ៉ាងណា ដល់ចឹងចេះតែគាំទ្រគាត់ ព្រោះគាត់ដឹកនាំល្អមួយដែរ ចង់និយាយថាគេធ្លាប់បានជួបប្រទះ បានដឹកនាំល្អមួយដែរ ។ ចឹងអាចគាំទ្រច្រើន ។

ដានី ៖ សុន សេន គេអត់គាំទ្រទេ?

អឿន ៖ បាទ!

ដានី ៖ ចុះអៀង សារី?

អឿន ៖ អៀង សារី ក៏ ផុសចេញពីអៀង សារីនេះឯង បានទៅជាផ្ដាច់ខ្លួនចឹង ។ មានតែអៀង សារីទេ ដែលគាត់ផ្ដល់គំនិតមួយ ដើម្បីបំបាត់ ចង់ថាផ្ដួលរំលំសុន សេននឹងឲ្យចេញ ។ ដល់អ៊ី ឈានគាត់, សុខភាព ហើយនឹងអ៊ី ឈាន គាត់ផ្ដល់មតិគ្នាទៅគាត់ធ្វើ ។ ដល់ធ្វើទៅថាធ្វើល្មមទេ អ៊ី ឈាន គាត់នឹកឃើញខ្លាចដូចសម័យគាត់ធ្លាប់ជួបប្រទះកាលពីប៉ុលពត នៅនោះនៅខាងកោះកុងនឹង គាត់ថា ។ ដល់ចឹង ខ្លាចរបៀបនឹង គាត់ក៏សុខចិត្តថារើបំរាស់ឲ្យខ្លាំងបណ្ដោយ សម្រេចថាធ្វើឲ្យដាច់បិតតែម្ដង ។ ដល់ចឹងបានទៅជាកើតទៅជាសមាហរណកម្ម ។

ដានី ៖ ស្រុកភូមិយើងនេះ ទើបដាក់ឈ្មោះកើតក្រោយ ឈ្មោះភូមិ ឃុំ ស្រុកអីនឹង កើតក្រោយ ទេ ពេលសមាហរណកម្មហើយនឹង?

អឿន ៖ បាទ!

ដានី ៖ ចុះពូ ដល់ពេលសមាហរណកម្មហើយ មានតួនាទីអីទៀតទៅ?

អឿន ៖ អត់ទេ បើនិយាយទៅថា សមាហរណកម្មហើយនឹងខ្ញុំនៅគេឲ្យកាន់ក្តាប់ កងកម្លាំងគេហៅថាសេនាជន ៣០នាក់ដែរ ។ កាលនឹងនៅរួមគ្នាជាមួយប៉ុស្តិ៍ប៉ូលីស ប៉ុស្តិ៍អីនឹង ដល់ក្រោយមក គេរំលាយកងសេនាជនចេញទៅ ខ្ញុំក៏អស់មានតួនាទីអីទៅ ។

ដានី ៖ ឥឡូវពូប្រជាជនសុទ្ធសាធ?

អឿន ៖ បាទ!

ដានី ៖ អត់មានធ្វើអីទៀតទេ?

អឿន ៖ បាទ!

ដានី ៖ ចុះភូមិនេះ ភូមិយើងនឹង ស្រុកអីនឹងចាប់ផ្តើមកើតតាំងពីឆ្នាំណា មុនសមាហរណកម្ម ឬតាំងពីក្រោយហើយ?

អឿន ៖ ក្រោយ ។

ដានី ៖ ក្រោយ?

អឿន ៖ សមាហរណកម្មហើយ បានបង្កើតភូមិ បង្កើតឃុំ បង្កើតស្រុក ។

ដានី ៖ ដូចឈ្មោះអី យើងដាក់យ៉ាងម៉េចទៅ?

អឿន ៖ កាលពីយើងអត់ទាន់សមាហរណកម្ម ចង់និយាយថាម្តុំអស់នេះគេហៅថាអូរសិប្បកម្ម ទៅខាងអូរចោទចឹងទៅគេហៅអូរចោទចឹង ។ ទៅចក្រីគេហៅចក្រី ភូមិចក្រីចាក់អីចឹង ទៅខាងម្តុំសានប៉ែតអី ហើយទៅម្តុំផ្សារកាប៊ីនអីនឹងគេហៅអូរអន្ទក់អីចឹង ។

ដានី ៖ គេហៅចឹង ។ ប៉ុន្តែម៉េចបានដាក់ឈ្មោះភូមិអីណាទៀត ភូមិកណ្តាល ភូមិសំរោងអីណាហូរហែលដូចឈ្មោះ?

អឿន ៖ បាទ! នេះក្រោយសមាហរណកម្មហើយមក គេបង្កើតទៅ គេដាក់ឈ្មោះតាម ដូចកន្លែងនឹងអូរ ប្រយុទ្ធចឹង គេដាក់ភូមិអូរប្រយុទ្ធទៅ កន្លែងនឹងសំរោង គេដាក់សំរោង ។

ដានី ៖ ម៉េចកន្លែងនឹងមានប្រយុទ្ធគ្នា ប្រយុទ្ធកន្លែងអូរនឹង?

អៀន ៖ អត់ទេ គ្មានប្រយុទ្ធទេ ចង់និយាយថាឈ្មោះនឹងមិនដឹងចេញពីណា ព្រោះខ្ញុំក្តាប់អត់បានដែរ ប៉ុន្តែកាលពីសម័យសង្គ្រាម សម័យយើងអត់ទាន់សមាហរណកម្ម ក៏គេហៅថាអូរប្រយុទ្ធដែរកន្លែងនឹង ។

ដានី ៖ ប៉ុន្តែក្នុងនឹងសុទ្ធតែព្រៃទេ មិនមែនភូមិចាស់ទេ?

អៀន ៖ បាទ! ព្រៃទាំងអស់ ។

ដានី ៖ ព្រៃទាំងអស់?

អៀន ៖ បាទ!

ដានី ៖ សុទ្ធតែដើមអីម្តុំៗនឹង?

អៀន ៖ អូ! ចំរុះ រៀបរាប់ពីដើមឈើ រាប់មិនអស់ វាមានឈើទាល មានគគីរ មានអាចម៍សេះ វាមានជ្រៀត មានស្រឡៅ មានអីគ្រប់ប្រភេទនឹង ។

ដានី ៖ ធំៗ ដើមឈើ?

អៀន ៖ បាទៗ ធំៗ ។

ដានី ៖ តែឥឡូវវាលអស់រលីង?

អៀន ៖ បាទ!

ដានី ៖ ឥឡូវសុទ្ធតែដើមស្វាយ ដើមអី?

អៀន ៖ បាទ!

ដានី ៖ ដើមស្វាយ ដើមដូង ដើមអីទើបដាំក្រោយៗទេ?

អៀន ៖ បាទ!

ដានី ៖ ចឹងកាលសមាហរណកម្មនឹងសុទ្ធតែព្រៃ យើងមិនអាចទៅមកបាន?

អៀន ៖ អឺ! មុនសមាហរណកម្ម យើងម្តុំនេះអស់នេះកើតផ្លូវដែរ គេឈូសផ្លូវ តែគេឈូសកាលនឹងកេឈូសយកឈើយកអីទេ គេធ្វើបរិសាត់ ចង់និយាយថាសម័យនឹងគេធ្វើបរិសាត់ឆ្នាំ៩៣-៩៤ គេធ្វើបរិសាត់នៅនេះ ។

ដានី ៖ បរិសាត់នឹងអីគេ?

អៀន ៖ បរិសាត់ ចេញឈើទិញអីនឹង ។ អានេះបើនិយាយភាសាថៃទេបរិសាត់ បើភាសាខ្មែរថាពួកថៅកែកាប់ឈើហ៊ុបនឹង ។

ដានី ៖ មកយើងដឹកឈើធ្វើផ្លូវ ដឹកឈើលក់ឲ្យថៃទៅ?

អៀន ៖ បាទ!

ដានី ៖ កាលមុនថៃ ចេញចូលដល់នឹងដែរ?

អឿន ៖ បាទ!មិនមែនត្រឹមប៉ុននឹង ថៃចូលទៅដល់យើង៣០ៗគំប្រង់ណា អាដួវមកពីបវេលមក ។

ដានី ៖ ចុះពូម៉េចដែលដូចថាកាលដែលយើងមិនទាន់សមាហរណកម្ម ហើយក្រោយសមាហរណកម្ម ម៉េចដែរ ដូចថាស្ថានភាពមានលក្ខណៈអីខុសគ្នាយ៉ាងម៉េច?

អឿន ៖ បាទ! មុនសមាហរណកម្មស្ថានភាពដូចថាវាខុសប្លែកគ្នាត្រង់ថា សម័យមុនសមាហរណកម្ម យើងចាយលុយវាមានតម្លៃ តែចូលមកដល់សម័យយើងសមាហរណកម្មហើយនេះ ចាយ លុយវាចេះតែថោកទៅៗ ដល់ចឹងវាសេដ្ឋកិច្ចកាន់តែខើច ដល់ចឹងវាមានការខ្វះខាត ច្រើន ។

ដានី ៖ ខ្វះខាត កាលមុនយើងសមាហរណកម្ម យើងដូចថាមានសំបូរចាយ?

អឿន ៖ បាទ!

ដានី ៖ ជីវភាពធូរធាជាង?

អឿន ៖ បាទ!

ដានី ៖ ម៉េចចឹងកាលនឹង?

អឿន ៖ កាលនឹងព្រោះចង់និយាយ តម្លៃទំនិញទិញដូរនឹងអត់មានស្រេចតែលើនាយទុន ស្រេចតែលើឈ្មួញកណ្ដាលទេ ។ តម្លៃទិញដូរអី កំណត់ថា ឧទាហរណ៍ថាពួកខ្ញុំនៅនេះ ខ្ញុំធ្វើចំការបានខ្លះ ។ ដល់ហើយពោត កំណត់តម្លៃ៣បាតគឺ៣បាតចឹង អត់មានឡើង អត់មានចុះ ។ ទេ!បើឡើងមាន តែចុះអត់ទេ សម្រាប់ឲ្យដូរកងទ័ពនៅនេះ ទោះបីពោតសើម ពោតស្ងួត ម៉េចក៏ដោយ ក៏នៅតម្លៃប៉ុននឹង ។

ដានី ៖ តែឥឡូវ?

អឿន ៖ ឥឡូវស្រេច អត់ទេ ស្រេចលើឈ្មួញកណ្ដាល ចង់ថា២ៗ ចង់ថា៣ទៅ ចង់ថា១បាតៗទៅ ។ ចឹងបានថា ឥឡូវវាពិបាកត្រង់ថាឈ្មួញអត់មានកំណត់តម្លៃច្បាស់លាស់ ។

ដានី ៖ ចុះដូចជីវភាពរបស់ពូវិញ ចុះកាលពីមុនសមាហរណកម្មយ៉ាងម៉េចដែរ ជីវភាពពូធូរធាជាង?

អឿន ៖ បាទ! សមាហរណកម្មហើយនេះ ក៏ខ្ញុំធូរធាដែរ តែទើបមកខ្ញុំវាខុស ត្រង់ថារកទៅវាខុស រកទៅអត់ចំទិសដៅ ដល់ចឹងវាខូចលុយចោលអស់ ។

ដានី ៖ ខូចលុយ?

អឿន ៖ បាទ!

ដានី : រកអីគេ ពូរកអី?

អឿន : អឺ!នេះ ខ្ញុំនៅទិញឈើទិញអីលក់ឲ្យថៃ ក្រោយមកក៏ធ្វើចំការទៅ ក៏ជួញដូរផ្សេងៗវាខុស យកលុយទៅឲ្យគេខ្ចីឲ្យអីចឹង ដល់ហើយគេអត់សង ដល់ចឹងអស់លុយទៀត ។

ដានី : ចុះពូខស្សរាប់ទៅលេងស្រុកទេ?

អឿន : បាទ! ខ្ញុំខស្សរាប់ទៅដែរ កាលពីខ្ញុំនៅមានម៉ូតូ ខ្ញុំម៉ាខែ កន្លះខែអីខ្ញុំទៅម៉ាថ្ងៃ២ថ្ងៃ ដល់ខ្ញុំអស់ម៉ូតូជិះខ្ញុំខ្ជិល ខ្ញុំនឹកឃើញខ្ជិលទៅណា ដើងពិបាកដើរផងអីផង ខ្ញុំលែងបានទៅណា ។

ដានី : ចុះកាលពីសម័យមុនសមាហរណកម្ម ពូមានទៅផ្ទះ?

អឿន : អត់ទេ ទៅមិនបាន ។

ដានី : ចុះបងប្អូនដឹងថាពូនៅនឹងអត់?

អឿន : បាទ!ដឹង ។

ដានី : ដឹងតាមរយៈអី?

អឿន : ដឹងកាលពី កាលយើងនៅជំរំសាយអេចនេះមានបងប្អូនគេចូលមកបាន កាលយើងបោះឆ្នោត៩៣ហើយ យើងមិនចេញចូលបាន គ្រាន់ថាយើងពីនេះទៅពិបាកចូល ដល់គេមកពីនឹងបេះចេញចូល ចង់មកៗ ចង់ទៅៗ ។

ដានី : ចុះបងប្អូនពូមានមកនៅខាងនេះជាមួយពូ បងប្អូនបង្កើត?

អឿន : អត់ទេ ។

ដានី : អត់?

អឿន : បាទ! នៅស្រុកនោះទាំងអស់ ។

ដានី : ស្រុកទាំងអស់?

អឿន : បាទ!

ដានី : ដល់ពេលនេះហើយ ពូខស្សរាប់ទៅដែរ ។ ពូម៉េចបានអត់ទៅនៅស្រុកវិញ?

អឿន : បើទៅឯងនឹងក៏ដូចយើងនៅនេះដូចតែគ្នា
យើងនៅនេះទៅវាមានមុខមានមាត់ខ្លះៗយើងឲ្យ រកស៊ីបាន ។ តែយើងទៅនោះ
អត់មានដីស្រែ....(ស្ដាប់មិនបាន) ។

ដានី : ចុះមិត្តភ័ក្តពូអីនៅស្រុកមានដែរអត់?

អឿន : មាន ច្រើន សុទ្ធតែអ្នកស្រែដូចតែយើងដែរ ។

ដានី : រាប់អានគ្នាជិតស្និតដែរ ឬក៏បែកគ្នាឃ្លាតទៅរៀងរសាយ?

អឿន ៖ អត់ទេ អាបែកគ្នាយូរម៉េចក៏នៅតែស្រឡាញ់គ្នាដដែល ។ មើលពួកម៉ាក់ខ្ញុំមួយនៅកាប៊ីន បែកគ្នាតាំងពីតូចៗ ហើយជួបនៅតែស្រឡាញ់គ្នាដដែល ។

ដានី ៖ ចុះពូៗមកដល់សព្វថ្ងៃនេះ ខាងរដ្ឋាភិបាលហើយនឹងអង្គការសហប្រជាជាតិ គេបង្កើតតុលា ការកាត់ទោស មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។

អឿន ៖ បាទ!

ដានី ៖ ដល់ឥឡូវនឹងដូចថាកាំងហ្គេចអ៊ីវហៅឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ហៅគុកទួលស្លែងនឹង ។

អឿន ៖ បាទ!

ដានី ៖ ត្រូវបានគេកាត់ទោសហើយ ។ ហើយខាងមុខឆាប់ៗនេះ គេនឹងកាត់ទោសមេដឹកនាំជាន់ខ្ពស់៤រូបទៀតដូចជា នួន ជា, ខៀវ សំផន, អៀង សារី និងប្រពន្ធរបស់គាត់ ។ ចុះបើតាមចិត្តរបស់ពូវិញ ពូយល់ឃើញម៉េចដែរ គេបង្កើតតុលាការកាត់ទោស?

អឿន ៖ ខ្ញុំក៏តាមខ្ញុំវិភាគនឹង វាគ្រាន់តែធ្វើដើម្បីយកលុយក៏មិនដឹង អានេះខ្ញុំវិភាគទេ គេគ្រាន់តែបង្កើតដើម្បីយកទឹកលុយសម្រាប់កសាងនៅប្រទេសកម្ពុជា ។ នេះតាមខ្ញុំយល់ ខ្ញុំវិភាគ ព្រោះខ្ញុំឃើញថារយៈពេលយូរមកហើយកាត់ទោសតាឌុចនេះ កាត់ទោសទៅវាអត់ឃើញទៅណាទៅ ។ ខ្ញុំឃើញមេធាវីមួយដែលការពារក្ដីឲ្យតាឌុចនេះ គេនិយាយម៉ាត់ៗ ប៉ុន្ដែគេនិយាយនឹង គេនិយាយនឹងសមហេតុសមផល ចង់សួរថាចុះនៅប្រទេសកម្ពុជាមានគុកមានប៉ុន្មាន ចង់សួរចឹងអានឹងមេធាវីការពារក្ដីគេសួរចឹងថា ក្នុងប្រទេសកម្ពុជាមានគុកប៉ុន្មានដល់ចឹងហេតុអីក៏ចាប់តាឌុចមួយ ចុះប្រធានគុកទាំងឡាយដែលនៅក្នុងប្រទេសកម្ពុជាម៉េចមិនចាប់មកផង អានឹងគេចង់ដឹងចឹង ហេតុផលវាចឹង ។ ចឹងបានសេចក្ដីថា មានកំហុសតាឌុច ក្រៅពីតាឌុចនឹងអត់ខុសទេ ។ ចុះសម័យនឹងវា ឲ្យតែមានគុកមានកាប់សម្លាប់ដូចគ្នាអីចឹងបានសេចក្ដីថា យើងវិភាគមើលទៅ គេនិយាយនឹងវាសមហេតុសមផលរបស់គេ ។

ដានី ៖ ចុះចំពោះមេដឹកនាំ៤នាក់ទៀត ដែលគេកំពុងកាត់?

អឿន ៖ នឹងហើយ ខ្ញុំកំពុងតាមដានបញ្ហានឹងមួយដែរ ព្រោះកំពូលៗថ្នាក់ដឹកនាំពីសម័យយើងប៉ុលពតនឹង ថ្នាក់កំពូលនឹង ចុះម៉េចហេតុអីមិនយកទៅផង ។

ដានី ៖ កំពូលអ្នកណាគេ?

អឿន ៖ ហើយចុះដូចគាត់និយាយមិញថា នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ ចឹងបានថា បើតាមខ្ញុំស្ដាប់ ហើយខ្ញុំវិភាគ កាត់ទោសមើលទៅវាដូចថាមិនចេញទៅណាទេ

តែកាត់ទោសអ្នកទាំងអស់នឹង ក៏កាត់ទោសសម្ដេចតាដែរ ព្រោះធាតុដើម បើតាមខ្ញុំដឹង ធាតុដើមគឺសម្ដេចតាអ្នកបង្កើតខ្មែរក្រហម ។ ចឹងបានសេចក្ដីថាបើកាត់ទោស កាត់ទាំងអស់ ដូចសម្ដេចតេជោរាល់ថ្ងៃនឹង សម្ដេចតេជោហ៊ុន សែន រាល់ថ្ងៃក៏គាត់ខ្មែរក្រហមដូច គ្នាដែរ ។ ហើយចឹងបានសេចក្ដីថា អានេះខ្ញុំវិភាគតាមខ្ញុំយល់ទេ តែមិនដឹងថាគេចង់ធ្វើ របៀបណាក៏ខ្ញុំអត់យល់ដែរ ។

ដានី : បើតាមច្បាប់កាត់ទោសខ្មែរក្រហមនឹង យើងកាត់ទោសតែ ឃើញច្បាប់គេសរសេរ ដែល ខ្ញុំធ្លាប់អាន គេកាត់ទោសតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំង ឡាយណា ដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងសម័យ កម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ៧៩ ។

អឿន : បាទ!

ដានី : ហើយចំពោះមេដឹកនាំជាន់ខ្ពស់ ដូចពូដឹងហើយប៉ុល ពត គាត់ស្លាប់ហើយ តាម៉ុកអីក៏គាត់ស្លាប់អស់ហើយ សុន សេន ក៏គាត់ស្លាប់ ។ ហើយអ្នកដែលនៅដូចជានួន ជា, អៀង សារី, ខៀវ សំផន ហើយប្រពន្ធគាត់មានតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ ។

អឿន : បាទ!

ដានី : ហើយចំពោះសម្ដេចអីៗកាលពីសម័យឆ្នាំ៧៥ នេះនឹង ខាងកម្ពុជាប្រជាធិបតេយ្យបានយាងសម្ដេចឲ្យធ្វើជាប្រមុខរដ្ឋៗ ហើយផឲ្យសម្ដេចគង់នៅក្នុងវាំង ។ ដល់ពេលក្រោយមកសម្ដេចបានលាលែងពីប្រមុខរដ្ឋនៅឆ្នាំ១៩៧៦ ។ ដល់ពេលសម្ដេចលាលែងទៅ ខាងរបបកម្ពុជាប្រជាធិបតេយ្យនឹង បានឃុំព្រះអង្គនៅក្នុងវាំងរហូត ។ ចឹងព្រះអង្គអត់មានតួនាទីអីទេ បន្ទាប់ពីព្រះអង្គបានលាលែងនៅឆ្នាំ៧៦ ដោយសារបក្សកុម្មុយនីសកម្ពុជាមិនបានប្រគល់អំណាចអីឲ្យ ។ បានឲ្យតែឈ្មោះទេ ឲ្យឈ្មោះថាសម្ដេចជាប្រមុខរដ្ឋ ។ ចឹងសម្ដេចបានសម្រេចចិត្តលាលែងឆ្នាំ៧៦ ហើយបន្ទាប់ពីលាលែងទៅ ខាងកម្ពុជាប្រជាធិបតេយ្យនឹង ឃុំព្រះអង្គនៅក្នុងវាំង អត់ឲ្យព្រះអង្គធ្វើចលនាអីទាំងអស់ មានគេយាម ដូចថាព្រះអង្គធ្វើអីចង់ទៅណាមានអ្នកនេះ ។ ហើយចំពោះពូមានប្រសាសន៍ថា សម្ដេចតេជោក៏ខ្មែរក្រហម ប៉ុន្តែកាលនឹងគាត់មានតួនាទីមួយជាថ្នាក់ មិនមែនក្នុងច្បាប់ដែលគេចែងមកសម្រាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម គេកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ ។ អានេះតាមច្បាប់ ទៅតាមការយើងវិភាគ ហើយចំពោះឌុច គាត់មិនមែនមេដឹកនាំជាន់ខ្ពស់

ខ្មែរក្រហមទេ ប៉ុន្តែគាត់គឺជាជនម្នាក់ដែលទទួលខុសត្រូវចំពោះការសម្លាប់មនុស្សអស់ជាង ១ម៉ឺននាក់ ដែលជាប់នៅគុកទួលស្លែង ។ ហើយមួយទៀត ដែលមេធាវី ដែលគាត់និយាយថា ម៉េចចាប់តែគាត់ៗប្រធានគុកមួយ ហើយប្រធានគុកផ្សេងៗទៀត១៩៦ ទៀតម៉េចមិនចាប់គាត់ ។ ពីព្រោះប្រធានគុកផ្សេងៗទៀត យើងអត់ពត៌មាន យើងអត់មានដឹងថាគាត់នៅរស់ អត់ដឹងថាគាត់នៅណា យើងអត់មានពត៌មាន គាត់នៅណា សព្វថ្ងៃនេះ ហើយក្នុងគុកនេះចាប់ប៉ុន្មានសម្លាប់ប៉ុន្មានអីប៉ុន្មាន ។ យើងអត់មានដឹងថាមួយណាប្រធានគុក មួយណាដែលនៅរស់ទេ មកដល់សព្វថ្ងៃនេះខាងតុលាការគេៗអត់មានពត៌មាន ទាក់ទងពីនឹងទេ ។ បើសិនមានពត៌មានថាប្រធានគុកណាមួយដែលនៅរស់ ហើយគុកនឹង ស្លាប់អស់ប៉ុន្មាន ប្រហែលជាគេកសាងសំណុំ ប្រហែលជាគេកសាងជាសំណុំរឿងគេចោទ ប្រកាន់ ហើយគេចោទដូចតែគ្នានឹង ។ តែគេអត់ដឹង តុលាការនឹងគេមិនមានពត៌មានមួយ ណាថាមួយណាឈ្មោះអីដែលជាប្រធានគុកណា ហើយគុកនឹងស្លាប់អស់ប៉ុន្មានអីប៉ុន្មាន គុកទួលស្លែង ។ គុកទួលស្លែងគេមានឯកសារ គេមានអ្នកដែលធ្លាប់ជាប់គុកនឹងនៅរស់ ហើយឯកសារទាំងឡាយដែលមាននៅគ្រប់គ្រង មានភស្តុតាងគ្រប់គ្រាន់ដែលគេសម្រាប់ចាប់គាត់ ។ ពូយល់ម៉េចដែរចឹង?

អឿន ៖ ខ្ញុំអត់យល់ដែរ ព្រោះកាលសម័យនឹង សម័យកម្ពុជាប្រជាធិបតេយ្យនឹង កាលនឹងបើតាម ខ្ញុំភ្លាប់ប្រវត្តិដូចថាខៀវ សំផន នឹងគាត់អត់មានបានទៅធ្វើការអីទៀតដែរ បើតាមដឹង ។ ខៀវ សំផន គាត់នៅក្រៅអត់ដឹង គាត់អត់មានបានលូកដៃ ដឹកនាំ កសាងដូចប៉ុល ពត ទេ ។ គាត់គ្រាន់ថាស្ថិតនៅក្នុងនឹងដែរ តែគាត់ដូចថាគាត់និយាយមិញចឹង និយាយថាដូចសម្តេចគាគឺឃុំទុកចោលនៅក្នុងវាំង ដូចថាខៀវ សំផន អត់មានបានប្រឡូកក្នុងការងារនឹងដែរ ។

ដានី ៖ តែទី១ គាត់អត់បានប្រឡូក ប៉ុន្តែ គាត់មានតួនាទីមួយជាប្រមុខរដ្ឋ គាត់អត់បានលាលែងដូចសម្តេចទេ ទទួលជាប្រមុខរដ្ឋរហូតដល់ឆ្នាំ១៩៧៩ ។ ចឹងទោះជាយ៉ាងម៉េច ក៏គាត់មានតួនាទីមួយជាមេដឹកនាំ គាត់ជាអ្នកទទួលខុសត្រូវដែរ ។ បើសិនជាគាត់ដឹងថា របបនឹងមានកំហុស ការកាប់សម្លាប់ ហើយគាត់សុំលាលែងយ៉ាងម៉េចពីការទទួលខុសត្រូវ អានឹង

ប្រហែលជារឿងមួយផ្សេងទៀត ។ អានេះជាការយល់ដឹងរបស់ខ្ញុំទេ ប៉ុន្តែតុលាការគេ ផ្លូវច្បាប់គេយ៉ាងម៉េចៗ ខ្ញុំមិនដឹងដែរ ។

អឿន ៖ ខ្ញុំអត់ដឹងដែរ ដល់ចឹងខ្ញុំមិនយល់ ខ្ញុំអត់ដែលបានរៀនច្បាប់ណា ។

ដានី ៖ ចឹងពូខ្ញុំអស់សំនួរត្រូវសួរនាំពូទៀតហើយ ពូមានអីចង់បន្ថែមនូវអ៊ីដែរខ្ញុំអត់បានសួរ?

អឿន ៖ អត់ទេ ខ្ញុំអត់មានចង់បន្ថែម ។ ខ្ញុំចង់ដឹងពីឈ្មោះខ្ញុំអីចឹង ឧទាហរណ៍ថាឈ្មោះខ្ញុំ (ស្តាប់មិនបាន) ជាគេមិនសូវគិតគូរអីចឹង ចេះចង់ដឹងដែរ ទោះបីជាសួរគាត់ៗអត់ដឹងដែរ ។ ចឹងបានជួបអ្នកផ្សេង ខ្ញុំចង់ដឹងជីវិតខ្ញុំសម្រេចថា កាលពីសង្គ្រាមចេះគេប្រើខ្ញុំបាន តែដល់ខ្ញុំសមាហរណកម្មហើយ ខ្ញុំមានគ្រោះថ្នាក់ដាច់ដៃដាច់ជើងចឹងទៅ វាទៅជាបំភ្លេចខ្ញុំ ។ តើគេមើលឆាយដល់ខ្ញុំអត់ ថាខ្ញុំមិនចេះរកស៊ីរកអី ។ មនុស្សតែអស់អវៈយវៈមួយណាហើយ គឺមិនអាចរកទៅបានទេ អត់អាចប្រើកម្លាំងខ្លាំងបានទេ ចេះចង់ដឹង ។

ដានី ៖ បាទៗ ខ្ញុំអរគុណច្រើន ពូ ។

“ចប់”